រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៧

# សេចក្តីថ្លែងការណ៍
# ស្តីអំពី
# ការវាយតម្លៃលើស្ថានភាព មុនថ្ងៃបោះឆ្នោត
# ជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤

សមាគម និងអង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍ស្តីពីការបោះឆ្នោតឆ្នាំ២០១៧យល់ឃើញថា ការចាត់ចែងការបោះឆ្នោតជាបច្ចេកទេស ដោយ គ.ជ.ប មានចំណុចវិជ្ជមានច្រើន។ បរិយាកាសនយោបាយ និងសន្តិសុខ គឺស្ថិតនៅស្ថានភាពគ្មានអំពើហឹង្សាធ្ងន់ធ្ងរ ដែលធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានដល់ការចាត់ចែងការបោះឆ្នោត សេរីភាពសិទ្ធិនយោបាយនៃគណបក្សប្រកួតប្រជែង សមាគម អង្គការសង្គមស៊ីវិល និងម្ចាស់ឆ្នោត។ យើងមានជំនឿថា នឹងមានសន្តិសុខ សុវត្ថិភាពសម្រាប់ដំណើរបោះឆ្នោត និងការប្រកាសលទ្ធផលបោះឆ្នោត។ ខាងក្រោមនេះ ជាការវាយតម្លៃលើចំណុចសំខាន់នៃស្ថានភាព និងដំណើរការចាត់ចែងមុនថ្ងៃបោះឆ្នោត៖

- **ក្រមខណ្ឌច្បាប់៖**
  មានចំណុចវិជ្ជមានខ្លះ និងអវិជ្ជមានខ្លះដែលទាក់ទិននឹងច្បាប់ ស្តីពីការបោះឆ្នោត និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ មានតែច្បាប់ ស្តីពីវិសោធកម្មគណបក្សនយោបាយមានចំណុចអវិជ្ជមានជាងមុន។
- **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត៖**
  គ.ជ.ប ចាត់ចែងការងាររបស់ខ្លួនបានល្អប្រសើរជាងមុនដូចជា៖ ការជ្រើសរើស និងតែងតាំងមន្ត្រីបោះឆ្នោត ការបំពេញភារកិច្ច ការរៀបចំផែនការ និងវគ្គបណ្តុះបណ្តាល ការអនុវត្តន៍ច្បាប់ និងបទបញ្ជា និងនីតិវិធី។
- **បញ្ជីឈ្មោះបោះឆ្នោត៖**
  បញ្ជីឈ្មោះបោះឆ្នោតមានគុណភាព និងភាពត្រឹមត្រូវល្អប្រសើរជាងមុន។
- **ការចុះឈ្មោះបញ្ជីបេក្ខជនគណបក្សនយោបាយ៖**
  ការចុះឈ្មោះបញ្ជីបេក្ខជនគណបក្សនយោបាយ មានលក្ខណៈវិជ្ជមាន ព្រោះមានគណបក្សនយោបាយចំនួន១២ បានចុះបញ្ជីបេក្ខជន ដើម្បីឈរឈ្មោះប្រកួតប្រជែង។ ហើយគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិបានចុះបញ្ជីបេក្ខជនរបស់ខ្លួនគ្រប់ឃុំ/សង្កាត់។ បេក្ខជនស្ត្រីនៃគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ស្ថិតនៅលំដាប់លេខរៀងខ្ពស់នៃបញ្ជីបេក្ខជន។

- **ការឃោសនាបោះឆ្នោត**
  ការឃោសនាបោះឆ្នោតមានលក្ខណៈវិជ្ជមាន និងមានដំណើរយ៉ាងរលូន ដោយមិនមានហឹង្សា និងទំនាស់រវាងគណបក្សរហូតរារាំងដល់សកម្មភាពឃោសនាឡើយ ហើយមានការចូលរួមយ៉ាងសកម្មពីអ្នកគាំទ្រគណបក្សនយោបាយ។ប៉ុន្តែនៅមានការរឹតត្បិតពីអាជ្ញាធរ ក្នុងការប្រើប្រាស់ទីធ្លាសាធារណៈ និងសេរីភាពបញ្ចេញមតិ។ ទូរទស្សន៍ឯកជនមិនអនុវត្តតាមគោលការណ៍សមភាព និងសេចក្តីណែនាំរបស់ គ.ជ.ប។ គណបក្សនយោបាយមិនមានរបាយការណ៍ ឬព័ត៌មានច្បាស់លាស់អំពីប្រភពចំណាយ និងខ្ទង់ចំណាយក្នុងការរៀបចំសកម្មភាពឃោសនាបោះឆ្នោត។
- **ការត្រៀមរៀបចំការបោះឆ្នោត និងរាប់សន្លឹកឆ្នោត**
  ការត្រៀមរៀបចំការបោះឆ្នោត និងរាប់សន្លឹកឆ្នោតមានលក្ខណៈល្អប្រសើរច្រើនដូចជា ការចេញវិធានការ០៥ចំណុច ដើម្បីធានាអ្នកបោះឆ្នោតម្នាក់បោះឆ្នោតបានតែម្តង ដើម្បីទប់ស្កាត់ការបោះឆ្នោតលើសពីចំនួនម្តង(១) ការត្រៀមសំភារៈសម្រាប់ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ការផ្តល់សុពលភាពដល់អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយ ការបិទផ្សាយទម្រង់ ១១០២ នៅមុខការិយាល័យបោះឆ្នោត ស្នាក់ការ គឃ.សប និងផ្សព្វផ្សាយនៅលើគេហទំព័រ គ.ជ.ប ។ ការបោះពុម្ពសន្លឹកឆ្នោតបំរុងទុកចំនួនប្រមាណ ២០% ដែលធ្វើឱ្យមានការព្រួយបារម្ភអំពីការគ្រប់គ្រងភាពមិនប្រក្រតី ដែលអាចកើតមានឡើង។
- **បរិយាកាសនយោបាយ**
  តាមការសង្កេតជាទូទៅ បរិយាកាសនយោបាយ និងសន្តិសុខមិនមានអំពើហឹង្សាធ្ងន់ធ្ងរ។ ប៉ុន្តែមានការប្រើប្រាស់សារនយោបាយរបស់មន្ត្រីរដ្ឋអំណាចជាន់ខ្ពស់មួយចំនួន ដែលនាំឲ្យមានការព្រួយបារម្ភ និងភ័យខ្លាចដល់ប្រជាពលរដ្ឋ។

សមាគម និងអង្គការសង្គមស៊ីវិលនៃបន្ទប់ស្ថានការណ៍អំពាវនាវដល់គ្រប់គណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតចូលរួមអនុវត្តតាមច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងទទួលយកលទ្ធផលនៃការបោះឆ្នោតនាពេលខាងមុខនេះ និងអំពាវនាវពលរដ្ឋជាម្ចាស់ឆ្នោតចេញទៅបោះឆ្នោតតាមឆន្ទៈរបស់ខ្លួន និងចូលរួមធ្វើជាសាក្សីនៃលទ្ធផលឆ្នោត ក្រោយពីសន្លឹកឆ្នោតត្រូវបានរាប់ និងប្រកាសលទ្ធនៅការិយាល័យបោះឆ្នោតនាថ្ងៃបោះឆ្នោត។

**ទំនាក់ទំនងព័ត៌មានៈ**

| | | | |
|---|---|---|---|
| 1. | លោក គល់ បញ្ញា | នាយកប្រតិបត្តិ COMFREL | ០១២ ៩៤ ២០ ១៧ |
| 2. | លោក សំ គន្ធាមី | នាយកប្រតិបត្តិNICFEC | ០១២ ៨២ ២២ ៧៣ |
| 3. | លោក យង់ គិមអេង | នាយកប្រតិបត្តិ PDP-Center | ០១៦ ៨២ ៨២ ១១ |
| 4. | លោក ជាង សុខា | នាយកប្រតិបត្តិអង្គការ YRDP | ០១២ ៣៦ ០៤ ៦៤ |
| 5. | លោក មឿន តុលា | នាយកប្រតិបត្តិ Central | ០៩៣ ៥៥ ៦៦ ៤៣ |